**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត

## របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសទិវាទេសចរណ៍ពិភពលោក នៅថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៨ ក្រោមប្រធានបទ "វិស័យទេសចរណ៍ និងនិន្នាការផ្លាស់ប្តូរទៅរកប្រព័ន្ធឌីជីថល"

(Tourism and the Digital Transformation)

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ!
- ជនរួមជាតិជាទីស្នេហា !

ខ្ញុំព្រះករុណាខ្ញុំ មានក្តីសោមនស្សបំផុតដោយបានចូលរួមជាមួយជនរួមជាតិ និងប្រជាជាតិនានានៅទូទាំងពិភពលោក ក្នុងឱកាសអបអរសាទរទិវាទេសចរណ៍ពិភពលោក នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ ក្រោមប្រធានបទ "វិស័យទេសចរណ៍ និងនិន្នាការផ្លាស់ប្តូរទៅរកប្រព័ន្ធឌីជីថល - Tourism and the Digital Transformation"។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំព្រះករុណាខ្ញុំ សូមវាយតម្លៃខ្ពស់ចំពោះអង្គការទេសចរណ៍ពិភពលោកដែលតែងយកចិត្តទុកដាក់ខ្ពស់លើការជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ពិភពលោក និងការលើកកម្ពស់តួនាទីដ៏សំខាន់នៃវិស័យទេសចរណ៍ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងកសាងសង្គមប្រកបដោយបរិយាប័ន្ន។

ទិវាទេសចរណ៍ពិភពលោកជាព្រឹត្តិការណ៍ដ៏មានសារៈសំខាន់សម្រាប់ជំរុញភាគីពាក់ព័ន្ធនានារួមមាន ផ្នែកសាធារណៈ ផ្នែកឯកជន ដៃគូអភិវឌ្ឍន៍ អង្គការ ប្រជាពលរដ្ឋ និងភ្ញៀវទេសចរឲ្យកាន់តែយល់ច្បាស់អំពីតួនាទី និងអត្ថប្រយោជន៍នៃវិស័យទេសចរណ៍ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថាន។

រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា មានសេចក្តីរីករាយក្នុងការចូលរួមប្រារព្ធ ទិវាទេសចរណ៍ពិភពលោកឆ្នាំ២០១៨ ជាមួយពិភពលោកទាំងមូល ហើយយកឱកាសនេះ ដើម្បីអបអរសាទរចំពោះសមិទ្ធផលទេសចរណ៍កម្ពុជា និងលើកទឹកចិត្តគ្រប់ភាគីពាក់ព័ន្ធ បន្តគាំទ្រការអភិវឌ្ឍទេសចរណ៍កម្ពុជាសំដៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិនៅឆ្នាំ២០៣០ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ជាក់ស្តែង ប្រធានបទនៃទិវាទេសចរណ៍ពិភពលោកឆ្នាំ២០១៨ នេះ ប្រារព្ធធ្វើឡើងស្របពេលដែលកម្ពុជា ក៏ដូចជាអាស៊ានបានកំពុងរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹង

បដិវត្តន៍ឧស្សាហកម្ម ជំនាន់ទី៤ (៤.០)។ យើងដឹងហើយថា ចរន្តនៃការរីកចម្រើនវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដែលហៅថាបដិវត្តន៍ឧស្សាហកម្មទី៤ បានក្លាយទៅជាកត្តាគន្លឹះមួយកំណត់នូវនិន្នាការវិវត្តនៃសង្គម-សេដ្ឋកិច្ចក្នុងគ្រប់ទិដ្ឋភាព ជាមួយនឹងការបង្កើតឡើងទាំងកាលានុវត្តភាព ទាំងបញ្ហាប្រឈមសម្រាប់សកលលោកទាំងមូល។

ជាការពិត ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នៃរដ្ឋសភាអាណត្តិទី៦ នេះ កម្ពុជាបានត្រៀមលក្ខណៈសម្បត្តិក្នុងការសម្របខ្លួន និងបដិវត្តន៍ឧស្សាហកម្មទី៤ ខណៈដែលបដិវត្តន៍ឧស្សាហកម្មទី៤ កំពុងបង្ហាញពីការរីកចម្រើននៃបច្ចេកវិទ្យានៅក្នុងពិភពលោក ដែលជះឥទ្ធិពលយ៉ាងខ្លាំងលើការកំណត់ឡើងវិញនូវកត្តាផលិតកម្ម ឥរិយាបថការប្រើប្រាស់ និងរចនាសម្ព័ន្ធសេដ្ឋកិច្ច ដូចជាការប្រើប្រាស់បច្ចេកវិទ្យា បញ្ញាសិប្បនិមិត្ត (AI) ការប្រើប្រាស់មនុស្សយន្ត (Robot) ការបោះពុម្ព 3D...។ល។ ដែលបច្ចេកវិទ្យាទាំងនេះ បានធ្វើឲ្យមានការផ្លាស់ប្តូរយ៉ាងលឿននូវក្នុងល្បឿនមួយដែលមិនធ្លាប់មានពីមុនមកក្នុងវិស័យផលិតកម្ម អប់រំ សុខាភិបាល ទីផ្សារការងារ ពាណិជ្ជកម្មទេសចរណ៍ ធុរកិច្ច រដ្ឋបាលសាធារណៈ និងបច្ចេកវិទ្យា។ល។ នាពេលបច្ចុប្បន្ននេះ ឌីជីថលូបនីយកម្មបានក្លាយទៅជាកាតាលីករកំណើនថ្មីមួយ តាមរយៈការបង្កើនផលិតភាព និងប្រសិទ្ធភាពការងារ និងអនុញ្ញាតឲ្យសហគ្រាសធុនតូច និងមធ្យមមានលទ្ធភាពផ្សាភ្ជាប់ទៅនឹងច្រវាក់ផលិតកម្មតំបន់ និងពិភពលោក និងស្វែងរកនវានុវត្តន៍ភាពនៅក្នុងទំនិញ ឬសេវាកម្មថ្មីៗ និងអនុញ្ញាតឲ្យប្រទេសដែលអភិវឌ្ឍន៍តិចតួច ឬមានសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍អាចចាប់យកបច្ចេកវិទ្យាថ្មីៗ ដើម្បីមានឱកាសអាចហក់ឡើងរំលងឧស្សាហកម្មបែបប្រពៃណីចូលក្នុងឧស្សាហកម្មបែបទំនើប។

ជាមួយនឹងក្តីរំពឹងថាបដិវត្តន៍ឧស្សាហកម្ម ៤.០ នឹងនាំមកនូវការអភិវឌ្ឍជាវិជ្ជមានសម្រាប់ប្រជាជាតិទាំងមូល ក្នុងនោះក៏មានវិស័យទេសចរណ៍កម្ពុជា បដិវត្តន៍នេះក៏អាចនាំមកនូវភាពកង្វល់ច្រើន និងបញ្ហាប្រឈមមួយចំនួន ដូចជាការបាត់បង់ការងារ ការទាមទារឲ្យមនុស្សមានកម្រិតអប់រំ និងជំនាញខ្ពស់ ការទទួលបាននូវផលប្រយោជន៍កាន់តែមិនស្មើគ្នា ដោយសារភាពមិនស្មើគ្នានៃឱកាសទទួលបាននូវចំណេះដឹង និងបច្ចេកវិទ្យា ឧក្រិដ្ឋកម្ម ឬបទល្មើសពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មាន ដែលអាចប៉ះពាល់ដល់សន្តិសុខជាតិ និងសន្តិសុខតំបន់ទាំងមូល និងសន្តិសុខតាមប្រព័ន្ធអ៊ីនធើណេត (Cyber Security)។ល។

ក្នុងស្មារតីនេះ ដើម្បីចាប់យកនូវការអភិវឌ្ឍជាវិជ្ជមាន និងកាត់បន្ថយកង្វល់ និងធានាឲ្យបាននូវទស្សនទាន "បច្ចេកវិទ្យាទំនើបសម្រាប់វិស័យទេសចរណ៍ វិស័យទេសចរណ៍សម្រាប់បច្ចេកវិទ្យាទំនើប ឬអាចហៅបានថា ការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយភាពវៃឆ្លាត - Smart Tourism" រាជរដ្ឋាភិបាលកម្ពុជានឹងអនុវត្តនូវវិធានការណ៍មួយចំនួន ដូចខាងក្រោម៖

- ផ្សាភ្ជាប់ចក្ខុវិស័យទេសចរណ៍ឆ្នាំ២០៣០ រួមជាមួយអំពីឧស្សាហកម្ម ៤.០ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងបរិយាប័ន្ន ដោយផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នៃរដ្ឋសភាអាណត្តិទី៦ ព្រមទាំងរួមបញ្ចូលកម្មវិធីអភិវឌ្ឍន៍សំខាន់ៗ លើផ្នែកបច្ចេកវិទ្យា ការអភិវឌ្ឍធនធានមនុស្សក្នុងឧស្សាហកម្មទេសចរណ៍ សំដៅធានាឲ្យបានថា "ការប្រើប្រាស់

នវានុវត្តន៍ និងភាពជឿនលឿនបច្ចេកវិទ្យា និងផ្តល់ឲ្យវិស័យទេសចរណ៍នូវកាលានុវត្តភាពដល់ការលើកកម្ពស់ប្រសិទ្ធភាពក្នុងវិស័យទេសចរណ៍ ការជម្រុញបរិយាប័ន្នភាពក្នុងឧស្សាហកម្មទេសចរណ៍ ការលើកកម្ពស់សិទ្ធិអំណាចដល់សហគមន៍មូលដ្ឋាន និងការគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាព និងការចូលរួមសម្រេចបាននូវរបៀបវារៈផ្សេងៗទៀតនៃការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ និងការត្រៀមទទួលភ្ញៀវទេសចរអន្តរជាតិ ១៥លាននាក់ នៅឆ្នាំ២០៣០"។

- រៀបចំកម្មវិធីពង្រឹងសមត្ថភាពមនុស្សក្នុងវិស័យទេសចរណ៍ តាមរយៈការលើកកម្ពុជាគុណភាពនៃការអប់រំកម្រិតខ្ពស់ ការបណ្តុះបណ្តាលជំនាញពាក់ព័ន្ធក្នុងឧស្សាហកម្មទេសចរណ៍ឲ្យស្របតាមនិន្នាការនៃការរីកចំរើនបច្ចេកវិទ្យា និងឌីជីថលរូបនីយកម្ម។
- លើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍ (Innovation) ក្នុងឧស្សាហកម្មទេសចរណ៍ ពង្រឹងនូវសមត្ថភាពសហគ្រិនភាពក្នុងការរៀបចំម៉ូឌែលធុរកិច្ច បង្កើតការងារថ្មី និងតម្រង់ទិសថ្មីរបស់សេដ្ឋកិច្ចឌីជីថល នាពេលអនាគត សម្រាប់ឧស្សាហកម្មទេសចរណ៍កម្ពុជា។

ជាការពិត កម្ពុជាជាប្រទេសមានសក្តានុពលខ្ពស់ក្នុងការចាប់យកនូវប្រយោជន៍ ដែលកើតចេញពីបដិវត្តន៍ឧស្សាហកម្មទី៤នេះ សម្រាប់វិស័យទេសចរណ៍កម្ពុជា ដោយហេតុថា៖ (១) ភាគលាភប្រជាសាស្ត្រ ដោយសារការកើនឡើងនូវចំនួនយុវជនមានចំណេះដឹង និងនិន្នាការចាប់យកបច្ចេកវិទ្យាឌីជីថលលឿន (២) ការកើនឡើងលឿននៃការប្រើប្រាស់ប្រព័ន្ធទូរស័ព្ទចល័ត និងទូរស័ព្ទវៃឆ្លាតជាមួយអត្រាប្រើប្រាស់ទូរស័ព្ទដៃខ្ពស់ (៣) លំហូរនៃការវិនិយោគក្រៅប្រទេសដែលនាំមកនូវបច្ចេកវិទ្យា និង (៤) ឌីជីថលរូបនីយកម្មបានកំពុងរីកចំរើនស្ទើរគ្រប់វិស័យសេដ្ឋកិច្ចសំខាន់ៗ ជាតួយ៉ាងដូចជាពាណិជ្ជកម្មអេឡិកត្រូនិច (E-Commerce) ស្របពេលដែលភ្ញៀវទេសចរកំពុងសម្របខ្លួនជាបណ្តើរៗក្នុងការប្រើប្រាស់នូវបច្ចេកវិទ្យាទាំងនេះ។ ដែលចំនុចទាំងអស់នេះហើយនឹងជះឥទ្ធិពលជាវិជ្ជមានដល់ការរីកចំរើននៃវិស័យទេសចរណ៍កម្ពុជា លើគ្រប់ទិដ្ឋភាពរាប់ទាំងការគ្រប់គ្រង ការផ្សព្វផ្សាយទេសចរណ៍កម្ពុជាជាដើម។

ក្នុងន័យនេះ ដើម្បីចូលរួមអបអរសាទរទិវាទេសចរណ៍ពិភពលោកឆ្នាំ២០១៨ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមស្នើស្ថាប័នពាក់ព័ន្ធ វិស័យឯកជន ប្រជាពលរដ្ឋ និងដៃគូអភិវឌ្ឍន៍ចូលរួមអភិវឌ្ឍទេសចរណ៍ឲ្យបានសកម្ម និងកាន់តែខ្លាំងក្លាថែមទៀត និងត្រៀមខ្លួនចាប់យកកាលានុវត្តភាពនៃឧស្សាហកម្មជំនាញទី៤ ក្នុងធុរកិច្ចក្នុងវិស័យទេសចរណ៍។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងទេសចរណ៍ជាសេនាធិការ បាននិងកំពុងដាក់អនុវត្តនូវយុទ្ធសាស្ត្រស្តីពី "**ការអភិវឌ្ឍវិស័យទេសចរណ៍វៃឆ្លាត - Smart Tourism**" ដោយបានកំពុងដាក់ចេញនូវការចុះបញ្ជីអាជ្ញាបណ្ណទេសចរណ៍តាមប្រព័ន្ធអនឡាញ ប្រព័ន្ធចំណាត់ថ្នាក់សណ្ឋាគារ និងភោជនីយដ្ឋានអនឡាញ ប្រព័ន្ធគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍តាមប្រព័ន្ធអនឡាញ ប្រព័ន្ធវាយតម្លៃចលនាប្រឡងប្រណាំង "**ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ**" តាមប្រព័ន្ធ QR-Code និងប្រព័ន្ធទូរស័ព្ទវៃឆ្លាត (Mobile App) ព្រមជាមួយការរីកចម្រើននៃមធ្យោបាយទូទាត់សម្រាប់ទេសចរណ៍តាមប្រព័ន្ធ QR-Code មធ្យោបាយដឹកជញ្ជូនវៃឆ្លាត (Pass App, Grape...។ល។) ក្នុងវិស័យទេសចរណ៍។

ជាថ្មីម្តងទៀត ខ្ញុំព្រះករុណាខ្ញុំ ជឿជាក់ថា ទិវាទេសចរណ៍ពិភពលោកឆ្នាំ២០១៨ ក្រោមប្រធានបទ "វិស័យទេសចរណ៍ និងនិន្នាការផ្លាស់ប្តូរទៅរកប្រព័ន្ធឌីជីថល - Tourism and the Digital Transformation" ជាឱកាសដ៏វិសេសវិសាលមួយសម្រាប់លើកស្ទួយវិស័យទេសចរណ៍ ដែលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គម អភិរក្សបរិស្ថាន កាត់បន្ថយភាពក្រីក្រ បង្កើនមិត្តភាព រក្សាសន្តិភាព និងពង្រឹងនូវតួនាទី និងសារៈសំខាន់នៃការប្រើប្រាស់បច្ចេកវិទ្យាទំនើប និងប្រព័ន្ធឌីជីថលក្នុងការអភិវឌ្ឍទេសចរណ៍កម្ពុជា ប្រកបដោយនិរន្តរភាព បរិយាប័ន្ន។

ឆ្លៀតឱកាសនេះ ខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវដល់ប្រជាពលរដ្ឋគ្រប់រូប ក្រសួងស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ ផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ សូមបន្តចូលរួមគាំទ្រ និងរួមចំណែកឲ្យកាន់តែសកម្មក្នុងការអភិវឌ្ឍទេសចរណ៍កម្ពុជា តាមរយៈការថែរក្សាសម្បត្តិវប្បធម៌ រក្សាប្រពៃណីជាតិ ការពារបរិស្ថាន លើកកម្ពស់គុណភាពផលិតផល និងសេវាកម្មទេសចរណ៍ រក្សាសុខសន្តិភាព និងធានាសុវត្ថិភាពសម្រាប់ភ្ញៀវទេសចរ។

ជាមួយគ្នានេះ ខ្ញុំព្រះករុណាខ្ញុំ សូមលើកទឹកចិត្តស្ថាប័នពាក់ព័ន្ធ និងផ្នែកឯកជន ចូលរួមឲ្យបានខ្លាំងក្លាក្នុងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ" ដើម្បីឲ្យកម្ពុជាស័ក្តិសមជា "ព្រះរាជាណាចក្រអច្ឆរិយៈ ផ្តល់ភាពកក់ក្តៅដល់ភ្ញៀវទេសចរ (Kingdom of Wonder- Feel the Warmth)" និងដើម្បីឲ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍ដ៏ទាក់ទាញមួយនៅក្នុងតំបន់ និងពិភពលោក។

ក្នុងឱកាសនេះដែរ ខ្ញុំព្រះករុណាខ្ញុំ សូមអញ្ជើញភ្ញៀវទេសចរអន្តរជាតិពីគ្រប់ទិសទីមកទស្សនាព្រះរាជាណាចក្រកម្ពុជាឲ្យកាន់តែច្រើន។

ជាទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមឲ្យទិវាទេសចរណ៍ពិភពលោកឆ្នាំ២០១៨ ជាផ្លូវការនៅទីក្រុងប៊ុយដាប៉េស្ត ប្រទេសហុងគ្រី ប្រព្រឹត្តទៅប្រកបដោយជោគជ័យ និងសូមថ្វាយពរ និងប្រសិទ្ធពរជ័យដល់សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិទាំងអស់ ទទួលបានជោគជ័យក្នុងការកិច្ចដ៏ឧត្តុង្គឧត្តម និងមានព្រះសុខភាព និងសុខភាពបរិបូណ៌។

ថ្ងៃ អង្គារ ១ រោច ខែ ភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៨

ហ៊ុន សែន